អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គនាយកដ្ឋានស្រាវជ្រាវ
នាយកដ្ឋានស្រាវជ្រាវថវិកា

# ព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច

## មាតិកា៖

- ការនាំចេញទំនិញរបស់ប្រទេសកម្ពុជាទៅកាន់ប្រទេសជប៉ុនមានការធ្លាក់ចុះនៅខែមករា ឆ្នាំ២០២១
- គម្រោងសាងសង់ព្រលានយន្តហោះនៅខេត្តកោះកុង ដែលមានតម្លៃ ៣៥០លានដុល្លារ នៅបន្តការ សាងសង់ បើទោះបីមានការរីករាលដាលនៃជំងឺកូវីដ-១៩
- ការប្រៀបធៀបផលិតផលតម្លៃនាំចេញប្រចាំខែមករា ឆ្នាំ២០២១ ថយចុះ ២០% ធៀបនឹងខែធ្នូ ឆ្នាំមុន
- ការនាំចេញវៀតណាមរយៈពេលពីរខែ កើន ២៧,១%
- គ្រឿងអេឡិចត្រូនិកជួយឱ្យទីក្រុងហូជីមិញក្លាយជាមជ្ឈមណ្ឌលផលិតកម្មឈានមុខគេ
- ការប្រែប្រួលនូវអាទិភាពចំណាយរបស់សហរដ្ឋអាមេរិកជាសញ្ញានៃ «ការខិតទៅរកទីបញ្ចប់នៃសេដ្ឋកិច្ចបែបរីហ្គីន»
- មិនមានការតម្លើងពន្ធលើប្រាក់ចំណូលបុគ្គលណាម្នាក់ ដែលរកប្រាក់ចំណូលបានតិចជាង ៤០ម៉ឺនដុល្លារអាមេរិកនោះទេ នេះបើយោងតាមអ្នកនាំពាក្យសេតវិមាន


ពិនិត្យ និងកែសម្រួលដោយ

- សួន ពុធថាវី អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- គឹម សុចិត្រា អគ្គនាយករង នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- ណុប ចាន់ធី ប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា
- ម៉ែន ខែមរៈ អនុប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា

ចងក្រង និងបូកសរុបដោយ

- ធីម ប៊ុនធឿន ប្រធានការិយាល័យវិភាគចំណូល-ចំណាយ

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### ការនាំចេញទំនិញរបស់ប្រទេសកម្ពុជា ទៅកាន់ប្រទេសជប៉ុនមានការធ្លាក់ចុះនៅខែមករា ឆ្នាំ២០២១



*ប្រភព៖ Khmer Tmes, 2021 (khmertimeskh.com), AFP*

តាមរយៈទិន្នន័យរបស់អង្គការពាណិជ្ជកម្មក្រៅប្រទេសរបស់ជប៉ុន (JETRO) បានបង្ហាញថា៖ ការនាំចេញរបស់ប្រទេសកម្ពុជាទៅកាន់ប្រទេសជប៉ុនបានធ្លាក់ចុះនៅក្នុងខែមករាបើធៀបនឹងរយៈពេលដូចគ្នាប្រចាំឆ្នាំ។

ប្រទេសកម្ពុជាបាននាំចេញទំនិញទៅកាន់ប្រទេសជប៉ុនក្នុងខែមករា មានតម្លៃ ១៣៨ លានដុល្លារ ដែលធ្លាក់ចុះ -៧,៨% បើធៀបនឹងខែមករា ឆ្នាំ២០២០។ ចំណែកឯការនាំចូលរបស់ប្រទេសកម្ពុជា ពីប្រទេសជប៉ុនក្នុងខែមករា ឆ្នាំ២០២១ មានចំនួន ៣៧លានដុល្លារ ដែលកើនឡើង ១៤,៤% ធៀបនឹងឆ្នាំ២០២០។

ពាណិជ្ជកម្មទ្វេភាគីរវាងប្រទេសទាំងពីរសរុបមានចំនួន ១៧៦ លានដុល្លារ នៅក្នុងខែមករាឆ្នាំនេះ ដែលមានការធ្លាក់ចុះ -៣,៧% ធៀបនឹងឆ្នាំមុន។ ពាក់ព័ន្ធនឹងបញ្ហានេះលោក លឹម ហេង អនុប្រធានសភាពាណិជ្ជកម្មកម្ពុជា បានមានប្រសាសន៍ថា៖ បើទោះជាមានការធ្លាក់ចុះ លោកនៅមានសុទិដ្ឋិនិយមថាសកម្មភាពពាណិជ្ជកម្មរវាងប្រទេសទាំងពីរ នឹងមានការងើបឡើងវិញដោយសារការទទួលបាននូវវ៉ាក់សាំងប្រឆាំងកូវីដ-១៩ ជាពិសេសនៅក្នុងប្រទេសកម្ពុជា។

ទំនិញដែលបាននាំចេញពីប្រទេសកម្ពុជាទៅកាន់ប្រទេសជប៉ុន មានដូចជា៖ សម្លៀកបំពាក់ កាបូប ស្បែកជើង គ្រឿងសង្ហារឹម គ្រឿងសំអាង ក្រដាស សម្ភារការិយាល័យ។ បើយោងតាមប្រសាសន៍ ឯកឧត្តមរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ការនាំចេញទំនិញរបស់ជប៉ុនមកកម្ពុជា រួមមាន៖ គ្រឿងម៉ាស៊ីនរថយន្ត គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារឹម ក្រណាត់ និងប្លាស្ទិក។ ក្នុងនោះដែរ ប្រទេសកម្ពុជាគ្រោងនឹងធ្វើកិច្ចពិភាក្សាជាមួយប្រទេសជប៉ុនអំពីលទ្ធភាពនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី និងជាមួយបណ្តាប្រទេសដទៃ។ កាលពីឆ្នាំមុន ពាណិជ្ជកម្មទ្វេភាគីរវាងកម្ពុជា និងជប៉ុនមានតម្លៃ

២ ប៊ីលានដុល្លារ គឺថយចុះ -៨% សម្រាប់ឆ្នាំ២០២០, ដែលក្នុងនោះការនាំចេញសរុបរបស់កម្ពុជាទៅជប៉ុន មានចំនួន ១,៦ ប៊ីលានដុល្លារធ្លាក់ចុះ- ៦,៧%។ *ដោយ សេន ចន្ទី*

*ប្រភព៖ khmertimeskh. ចេញផ្សាយថ្ងៃទី១៥ ខែមីនា ឆ្នាំ ២០២១*

## គម្រោងសាងសង់ព្រលានយន្តហោះ នៅខេត្តកោះកុង ដែលមានតម្លៃ ៣៥០លានដុល្លារ នៅបន្តការសាងសង់ បើទោះបីមានការរីករាលដាលនៃជំងឺកូវីដ-១៩



*ប្រភព៖ Phnom Penh Post, 2021 ($350M Koh Kong airport on track | Phnom Penh Post) -រូបថត SSCA*

អ្នកនាំពាក្យនៃរដ្ឋលេខា- ធិការដ្ឋានអាកាសចរស៊ីវិល (SSCA)បានឱ្យដឹងថា៖ ទោះបីជាមានការរីករាលដាលជំងឺកូវដ១៩ដោយសារព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ ដែលបានធ្វើឱ្យមានការរឹតបន្តឹងការធ្វើដំណើរទៅតំបន់ដែលពេញនិយមមួយចំនួន ដូចជាតំបន់ឆ្នេរសមុទ្រជាដើម ប៉ុន្តែព្រលានយន្តហោះអន្តរជាតិតារាសាគរនៅក្នុងខេត្តកោះកុងមិនបានដាក់លិខិតណាមួយ ដើម្បីស្នើសុំពន្យារពេលវេលា ដែលបានកំណត់ក្នុងការដាក់ឱ្យប្រតិបត្តិការនោះទេ។ បច្ចុប្បន្ន ក្រុមហ៊ុននេះនៅតែប្រកាន់ខ្ជាប់ការកំណត់ពេលវេលារបស់ខ្លួនដែលគ្រោងចាប់ផ្តើមប្រតិបត្តិការនៅពាក់កណ្តាលឆ្នាំ២០២១ បន្ទាប់ពីការសាងសង់ផ្លូវរត់ និងអគារទទួលអ្នកដំណើរត្រូវបានបញ្ចប់តាំងពីចុងឆ្នាំ២០២០ ហើយកំពុងដំណើរការសាកល្បង ដំឡើងគ្រឿងបរិក្ខារផ្សេងៗ និងរៀបចំស្នើសុំវិញ្ញាបនបត្រព្រលានយន្តហោះ ដែលត្រូវការពេលវេលាយ៉ាងហោចណាស់ពី ៦ ទៅ ៧ ខែ។

នៅក្នុងដំណាក់កាលដំបូង ក្រុមហ៊ុនគ្រាន់តែបើកឱ្យដំណើរការសាកល្បងជើងហោះហើរជាលក្ខណៈដួលមិនមែនលក្ខណៈទៀងទាត់នោះទេ គឺអាស្រ័យលើភាពធូរស្រាលនៃជំងឺកូវីដ-១៩ និងទំនុកចិត្តរបស់អ្នកដំណើរតែប៉ុណ្ណោះ នេះបើយោងតាមអ្នកនាំពាក្យដដែលនេះ។

ព្រលានយន្តហោះអន្តរជាតិនេះកំពុងអភិវឌ្ឍដោយក្រុមហ៊ុនចិន Tianjin Union Development Group (UDG) ដែលមានសមត្ថភាពអាចទទួលយន្តហោះចម្ងាយឆ្ងាយឲ្យចុះចត រួមមានយន្តហោះប្រភេទ Boeing 777 និងប្រភេទ Airbus A340។

ការសាងសង់ព្រលានយន្តហោះអន្តរជាតិនៅខេត្តកោះកុងមានដើមទុនវិនិយោគចំនួន ៤០ លានដុល្លារ ដែលជាការវិនិយោគរួមគ្នារវាងក្រុមហ៊ុនរបស់ ឯកឧត្តម លី យ៉ុងផាត់ និងក្រុមហ៊ុន Bangkok Airways Plc ត្រូវបានផ្អាកដំណើរការរហូតដល់ស្ថានការណ៍ជំងឺកូវីដ-១៩ ធូរស្រាលឡើងវិញ។

ទន្ទឹមនឹងនេះ វិស័យអាកាសចរណ៍មិនទាន់កើនឡើងវិញនោះទេ ដោយសារមានការបារម្ភជុំវិញការឆ្លងរីករាលដាលជំងឺកូវីដ-១៩ ក្នុងនោះដែរ ចរាចរណ៍នៃអ្នកដំណើរទាំងជាតិ និងអន្តរជាតិតាមព្រលានយន្តហោះអន្តរជាតិទាំង៣របស់កម្ពុជារួមមានៈ ព្រលានយន្តហោះអន្តរជាតិភ្នំពេញ ខេត្តសៀមរាប និងខេត្តព្រះសីហនុ បានធ្លាក់ចុះ ៨១,៣% កាលពីឆ្នាំមុនធៀបនឹងឆ្នាំ ២០១៩ ខណៈដែលចរាចរណ៍ទំនិញក៏បានធ្លាក់ចុះ ២៩,៩% ដោយសារការអាក់ខានដែលបណ្ដាល មកពីការរីករាលដាលជំងឺកូវីដ-១៩។ គួររម្លឹកផងដែរថា ព្រលានយន្តហោះអន្តរជាតិទាំង ៣ នៅក្នុងប្រទេសកម្ពុជាបានស្វាគមន៍អ្នកដំណើរចំនួន ១១,៦ លាននាក់ កាលពីឆ្នាំ ២០១៩ កើនឡើង ១០,២% ធៀបនឹងឆ្នាំ២០១៨ នេះបើយោងតាមរបាយការណ៍របស់ក្រុមហ៊ុន Cambodia Airports៕ *ដោយ សេន ចន្ទី*

*ប្រភព៖ Phnompenh post.com ចេញផ្សាយថ្ងៃទី១៦ ខែមីនា ឆ្នាំ ២០២១*

## តារាងប្រចាំសប្តាហ៍៖ ការប្រៀបធៀបផលិតផលតម្លៃនាំចេញប្រចាំខែមករា ឆ្នាំ២០២១ ថយចុះ ២០% ធៀបនឹងខែធ្នូ ឆ្នាំមុន

រូបខាងក្រោមនេះ បង្ហាញពីការប្រៀបធៀបការនាំចេញផលិតផលគ្រប់ប្រភេទ ក្នុងខែមករា ឆ្នាំ២០២១ គឺថយចុះ ២០% ធៀបនឹងខែធ្នូ ឆ្នាំមុន រួមមាន៖ សំលៀកបំពាក់ វាយនភ័ណ្ឌ អង្ករ ស្បែកជើង និងផលិតផលផ្សេងៗ នេះបើយោងតាមព្រឹត្តិបត្រពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម ដែលបានចេញផ្សាយនៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១។

ការនាំចេញផលិតផលនៅខែមករា ឆ្នាំ២០២១ មានការថយចុះស្ទើរលើគ្រប់មុខទំនិញទាំងអស់លើកលែងតែទំនិញស្បែកជើង និងវាយនភ័ណ្ឌ ដែលមានជាអាទិ៍ដូចជា៖ សំលៀកបំពាក់ថយ ១៤% អង្ករថយ ៦៨% កាបូបធ្វើដំណើរថយ ១២% កង់គ្មានសកម្មភាព ចំណែកផលិតផលផ្សេងៗ វិញថយចុះ ២៦% បើប្រៀបធៀបទៅនឹងខែធ្នូ ឆ្នាំ២០២០។ ចំណែក ស្បែកជើងកើន ៣% និងវាយនភ័ណ្ឌកើន ៤០% ធៀបនឹងរយៈពេលដូចគ្នា។

ទំនិញ ខាងលើទាំងអស់នេះ ត្រូវបាននាំចេញទៅទីផ្សារពិភពលោក និងមាននិន្នាការដូចខាងក្រោម បើធៀបនឹងខែធ្នូឆ្នាំមុន៖ សហរដ្ឋអាមេរិកមានការថយចុះ១៤% កាណាដាកើន ២៧% ជប៉ុនថយ៥៦% សហគមអឺរ៉ុបកើន៥% អាស៊ានថយ ២៦% ចិនថយ ៧២% កូរ៉េថយ ៥៣% និងប្រទេសផ្សេងៗទៀតថយ ២៨%។ សរុបជារួម ការនាំចេញផលិតផលគ្រប់ប្រភេទ ទៅកាន់ទីផ្សារ

ពិភពលោកនៅក្នុងខែមករា ឆ្នាំ២០២១ គឺថយចុះ ២០% បើធៀបទៅនឹងខែធ្នូ ឆ្នាំ២០២០៕ *ដោយ ឈន ហាំ*

**បញ្ជាក់៖ ទិន្នន័យនេះមិនរាប់បញ្ចូលតំបន់សេដ្ឋកិច្ចពិសេសទេ**

| ល.រ | ប្រភេទផលិតផល /ទីផ្សារគោលដៅ | ខែធ្នូឆ្នាំ២០២០ | ខែមករាឆ្នាំ២០២១ | ភាគរយ (%) |
|---|---|---|---|---|
| | **សរុបរួម** | **1,140,308,335.19** | **910,480,260.44** | **20.15%** |
| 1 | សំលៀកបំពាក់ | 553,214,738.22 | 473,546,112.22 | -14.40 |
| 2 | ស្បែកជើង | 89,758,835.75 | 92,357,933.97 | 2.90% |
| ៣ | វាយនភ័ណ្ឌ | 5,989,406.59 | 8,374,579.17 | 39.82% |
| 4 | អង្ករ | 96,128,602.32 | 30,757,914.76 | -68.00% |
| 5 | ការបូបធ្វើដំណើរ | 91,214,016.69 | 80,104,242.85 | -12.18% |
| 6 | កង់ | 0.00 | 0.00 | 0.00 |
| 7 | ផលិតផលផ្សេងៗ | 304,002,735.62 | 225,339,477.47 | -25.88% |

| ល.រ | ប្រភេទផលិតផល /ទីផ្សារគោលដៅ | ខែធ្នូឆ្នាំ២០២០ | ខែមករាឆ្នាំ២០២១ | ភាគរយ (%) |
|---|---|---|---|---|
| | **សរុបរួម** | **1,140,308,335.19** | **910,480,260.44** | **-20.15%** |
| 1 | សហរដ្ឋអាមេរិក | 323,798,788.96 | 277,229,982.37 | -14.38% |
| 2 | កាណាដា | 58,563,242.44 | 74,153,393.30 | 26.62% |
| ៣ | ជប៉ុន | 58,045,610.21 | 25,805,241.01 | -55.54% |
| 4 | សហគមអ៊ឺរ៉ុប | 264,978,435.16 | 279,104,030.59 | 5.33% |
| 5 | អាស៊ាន | 223,838,724.51 | 166,503,339.58 | 25.61% |
| 6 | ចិន | 138,459,081.80 | 38,882,402.80 | -71.92% |
| 7 | កូរ៉េ | 13,877,373.32 | 6,466,069.00 | -53.41% |
| 8 | ប្រទេសដ៏ទៃទៀត | 58,747,078.79 | 42,335,801.79 | -27.94% |

*ប្រភព៖ ក្រសួងពាណិជ្ជកម្មកម្ពុជា ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១*

## ព័ត៌មាន និងទិន្នន័យរបស់បណ្ដាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### ការនាំចេញវៀតណាមរយៈពេលពីរខែ កើន ២៧,១%



ប្រភព៖ Vietnam Economic News, 2021 (ven.vn)

ការនាំចេញនាំចូលរបស់វៀតណាមបានកើនដល់ ៩៧,៥ ពាន់លានដុល្លារ ក្នុងរយៈពេលពីរខែដំបូងនៃឆ្នាំនេះ គឺកើនឡើង ២៦,៧% ធៀបទៅនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ដោយសារការនាំចេញបានកើនឡើង ២៧,១% ដែលមានតម្លៃដល់៥០ពាន់លានដុល្លារ។ ការនាំចេញនោះរួមមាន អង្ករ ស្បែកជើង និងសម្ភារៈជាច្រើនទៀត។

នៅក្នុងខែដំបូងនៃឆ្នាំនេះ អង្ករក្រអូប ៦០តោនដំបូងត្រូវបានដឹកជញ្ជូនទៅទីផ្សារទីក្រុងឡុង ចក្រភពអង់គ្លេសក្នុងអត្រាពន្ធគយសូន្យ ក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអង់គ្លេស - វៀតណាម (UKVFTA) ។ ជាមួយគ្នានេះ ក្នុងរយៈពេលពីរខែដំបូងធៀបនឹងឆ្នាំមុន ការនាំចេញផលិតផលឈើបានកើនឡើង ៥១% ការនាំចេញសម្លៀកបំពាក់ និងវាយនភ័ណ្ឌបានកើនឡើង ៥,២%, ការនាំចេញទូរស័ព្ទចល័ត និងគ្រឿងបន្លាស់បានកើនឡើង ២៩,៤% ខណៈពេលដែលការនាំចេញស្បែកជើង ក៏បានកើនឡើង ១៥,៤% ផងដែរ។ ចំណែកឯទីផ្សារនាំចេញសំខាន់ៗរបស់វៀតណាម មានដូចជា អាមេរិក ចិន សហភាពអឺរ៉ុប ជប៉ុន សាធារណៈរដ្ឋកូរ៉េ

អូស្ត្រាលី និងប្រទេសសមាជិកអាស៊ាន ក៏បានបើកទ្វារទទួលទំនិញរបស់វៀតណាម ជាពិសេស ការនាំចេញរបស់វៀតណាមទៅអូស្ត្រាលីបានកើនឡើង ៦២% ដោយសារការនាំចេញគ្រឿងសមុទ្រកើនឡើងច្រើនជាងទ្វេដង។

ទោះបីជាយ៉ាងណា ប្រទេសវៀតណាម ក៏បានប្រឈមបញ្ហាលំបាកមួយចំនួនផងដែរ ក្នុងនោះមានកង្វះខាតកុងតឺន័រ (containers) ដែលនាំឱ្យមានការកើនឡើងនូវពន្ធគយក្នុងការដឹកជញ្ជូន។ កង្វះកុងតឺន័រនេះ បណ្តាលមកពីការកើនឡើងការនាំចេញដ៏ខ្លាំង និងការដាក់ឱ្យនៅដាច់ដោយឡែកនាវិកកប៉ាល់ក្នុងកំពង់ផែបរទេស។ លើសពីនេះ កាតលឿងសម្រាប់ការនេសាទខុសច្បាប់ ការនេសាទដែលមិនបានរាយការណ៍ និងការនេសាទគ្មានច្បាប់ (IUU) នៅតែជាបញ្ហាប្រឈម៕

*ដោយ វត្ថា វង្សវឌ្ឍនៈ*

*ប្រភព៖ គេហទំព័រសារព័ត៌មាន Vietnam Economic News ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១*

## គ្រឿងអេឡិចត្រូនិកជួយឱ្យទីក្រុងហូជីមិញក្លាយជាមជ្ឈមណ្ឌលផលិតកម្មឈានមុខគេ



*ប្រភព៖ Viet Nam News, 2021- (VietNam News), VNA/VNS រូបថត Thanh Vũ*

ក្រុមហ៊ុនអេឡិចត្រូនិចពហុជាតិកំពុងធ្វើការផ្លាស់ប្តូរដើម្បីបង្កើនការវិនិយោគ និងពង្រីកផលិតកម្ម ដើម្បីជួយឱ្យទីក្រុងហូជីមិញក្លាយជាមជ្ឈមណ្ឌលផលិតកម្មឈានមុខគេ។

ទីក្រុងហូជីមិញមានគម្រោងវិនិយោគផ្ទាល់ពីបរទេស (FDI) ចំនួន ៥០ ដោយមានទុនវិនិយោគជាង ៥ ពាន់លានដុល្លារអាមេរិក លើផ្ទៃដីជាង ៣២៦ ហិកតា។ ទីក្រុងនេះបានទាក់ទាញម៉ាកយីហោឈានមុខគេជាច្រើនក្នុងពិភពលោក រួមមាន ក្រុមហ៊ុន Intel, Samsung, First Solar, Furukawa Automotive Parts, និង Renesas។

នៅដើមឆ្នាំនេះ ទាំងក្រុមហ៊ុន Intel និងក្រុមហ៊ុន Samsung បានបង្កើនការវិនិយោគក្នុងពេលដំណាលគ្នា និងបានប្តេជ្ញាចិត្តក្នុងការវិនិយោគរយៈពេលវែងនៅវៀតណាម ទោះបីជាបច្ចុប្បន្នមានការរឹតត្បិតបណ្តាលមកពីការរាតត្បាតនៃជំងឺកូវីដ-១៩ ក៏ដោយ។ ក្នុងនោះ ក្រុមហ៊ុន Intel ផលិតផលវៀតណាម បានបង្កើន ទុនវិនិយោគចំនួន ៤៧៥ លានដុល្លារ ដែលធ្វើឱ្យមូលធនវិនិយោគសរុបរបស់ខ្លួនកើនឡើងដល់ជាង ១,៥ ពាន់លានដុល្លារ ខណៈពេលដែល ក្រុមហ៊ុន Samsung អេឡិចត្រូនិក HCMC CE Complex Co Ltd បានបង្កើនទុនវិនិយោគដល់ជា ២ពាន់លានដុល្លារ ដែលសាងសង់លើផ្ទៃដីជាង ៩៣ ហិកតា ក្នុងសមត្ថភាពផលិត ១៩លានផលិតផល ក្នុងមួយឆ្នាំ ដែលចំណូលជាមធ្យមប្រចាំឆ្នាំ ៤,២ ពាន់លានដុល្លារ និងបានរួមវិភាគទានច្រើនជាង ១១៨ លានដុល្លារ ដល់ថវិការដ្ឋ។

ក្រុមអ្នកជំនាញបាននិយាយថា ការផ្លាស់ប្តូរនេះ មិនត្រឹមតែបង្កើតការលើកទឹកចិត្តសម្រាប់ការនាំចេញប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ការគាំទ្រដល់អាជីវកម្មនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់របស់ក្រុមហ៊ុនSamsung ជាពិសេស អាជីវកម្មនៅក្នុងវិស័យគាំទ្រឧស្សាហកម្មនៅក្នុងទីក្រុងហូជីមិញ និងតំបន់ជិតខាង។

ទន្ទឹមនឹងនេះ ក៏មានក្រុមហ៊ុន First Solar Vietnam Manufacturing Co Ltd បានវិនិយោគសាងសង់រោងចក្រចំនួនពីរនៅឧទ្យានឧស្សាហកម្ម Đông Nam ដែលទំហំវិនិយោគមានចំនួន ៨៣០លានដុល្លារ ហើយនៅពេលរោងចក្រទាំងពីរដំណើរការពេញលេញ សមត្ថភាពសរុបរបស់ First Solar នឹងកើនឡើងដល់២,៨GW ក្នុងមួយឆ្នាំ។ ក្រុមហ៊ុននេះក៏បានបង្កើនសមត្ថភាពផលិតរបស់ខ្លួនទ្វេដងប្រហែល ៥,៣១លានម៉ូឌុលក្នុងមួយឆ្នាំ ដែលសមត្ថភាពផលិតរំពឹងទុកដំបូងមានត្រឹមតែ ២,៦លានម៉ូឌុលក្នុងមួយឆ្នាំ។ គេរំពឹងថា ផលិតផលនឹងត្រូវនាំចេញទៅអាមេរិក និងអឺរ៉ុប៕ *ដោយ វត្ថា វង្សវឌ្ឍនៈ*

*ប្រភព៖ គេហទំព័រសារព័ត៌មាន Viet Nam News ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២១*

## សេដ្ឋកិច្ចសកល

### ការប្រែប្រួលនូវអាទិភាពចំណាយរបស់សហរដ្ឋអាមេរិក ជាសញ្ញានៃ «ការខិតទៅរកទីបញ្ចប់នៃសេដ្ឋកិច្ចបែបរីហ្គីន (Reaganomics)»




*ប្រភព៖ CNBC News, 2021 (https://www.cnbc.com/2021/03/15/toogood-shift-in-us-spending-emphasis-almost-the-end-of-reaganomics.html)*

យោងតាមលោក Peter Toogood ប្រធានផ្នែកវិនិយោគនៃក្រុមហ៊ុន Emberk Group បានឱ្យដឹងថា ការប្រែប្រួលអាទិភាពចំណាយរបស់សហរដ្ឋអាមេរិក ក្រោមការដឹកនាំរបស់លោកប្រធានាធិបតី Joe Biden ជាសញ្ញា **«ការខិតទៅរកទីបញ្ចប់នៃសេដ្ឋកិច្ចបែបរីហ្គីន (Reaganomics)»** ដែលសេដ្ឋកិច្ចបែបរីហ្គីន គឺជាសំណុំនៃគោលនយោបាយសេដ្ឋកិច្ចត្រូវបានបង្កើតឡើងដោយអតីតប្រធានាធិបតី លោក Ronald Reagan អំឡុងទសវត្សរ៍ឆ្នាំ១៩៨០ ក្នុងគោលបំណងដើម្បីកាត់បន្ថយនូវការចំណាយរបស់រដ្ឋាភិបាល ពន្ធលើប្រាក់ចំណូល និងបទប្បញ្ញត្តិនានា ព្រមទាំងកាត់បន្ថយការផ្គត់ផ្គង់សាច់ប្រាក់ ដើម្បីទប់ស្កាត់ការកើនឡើងនៃអតិផរណា។

លោកប្រធានាធិបតី Biden បានចុះហត្ថលេខាលើច្បាប់ ស្តីពីកញ្ចប់ថវិកាសង្គ្រោះបន្ទាន់នូវទឹកប្រាក់ដ៏

ច្រើនសន្ទឹកសន្ធាប់ចំនួន ១,៩ទ្រីលានដុល្លារអាមេរិក ដែលថវិកានេះ នឹងផ្តល់នូវទឹកប្រាក់ចំនួន ១ ៤០០ដុល្លារអាមេរិក ដល់ប្រជាពលរដ្ឋអាមេរិកម្នាក់ៗ ប្រមាណ ១៥៩លាននាក់។ ទន្ទឹមនឹងនេះ ធនាគារកណ្តាលអាមេរិក បានសន្យាថា នឹងបន្តប្រើប្រាស់គោលនយោបាយរូបិយវត្ថុធូររលុងរបស់ខ្លួន និងបានបង្ហាញនូវឆន្ទៈក្នុងការពន្យារពេលការកំណត់គោលដៅអតិផរណានូវអត្រា ២% ប្រសិនបើចាំបាច់។

តាមរយៈការប្រែប្រួលនូវចំណាយមិនធ្លាប់មានពីមុនមករបស់សហរដ្ឋអាមេរិកបានបង្ហាញថា ទីផ្សារវិនិយោគកំពុងមានប្រតិបត្តិការល្អ។ ទន្ទឹមនឹងនេះ ទីផ្សារមូលបត្រក៏មានភាពប្រែប្រួលក្នុងរយៈពេលប៉ុន្មានសប្តាហ៍ថ្មីៗនេះ ដោយសារតែទិន្នផលប្រចាំឆ្នាំនៃមូលបត្របំណុល បានកើនឡើងជាមួយនឹងការរំពឹងទុកការកើនឡើងនូវអត្រាអតិផរណា ដែលនេះនឹងបង្កើនការព្រួយបារម្ភថា ធនាគារកណ្តាលអាចចាប់ផ្តើមដកចេញវិធានការជំរុញមួយចំនួនដែលកំពុងមាន។

ទោះជាយ៉ាងណា លោក Toogood បានគូសបញ្ជាក់ថា ប្រសិនបើ ការផ្លាស់ប្តូរនាពេលបច្ចុប្បន្នបរាជ័យ នោះសហរដ្ឋអាមេរិក និងប្រទេសសេដ្ឋកិច្ចធំៗផ្សេងទៀតអាចនឹងធ្លាក់ចូលក្នុងវិបត្តិសេដ្ឋកិច្ចរយៈពេលវែង ដូចបានគេមើលឃើញនៅក្នុងប្រទេសជប៉ុន។ ប៉ុន្តែ ប្រសិនបើវាជោគជ័យ អតិផរណាត្រូវបានគេរំពឹងថា នឹងកើនឡើងគួរឱ្យកត់សម្គាល់៕ *ដោយ ស៊ិន សុភារ៉ា*

*ប្រភព៖ គេហទំព័រសារព័ត៌មាន CNBC ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ ២០២១*

## មិនមានការតម្លើងពន្ធលើប្រាក់ចំណូលបុគ្គលណាម្នាក់ ដែលរកប្រាក់ចំណូលបានតិចជាង ៤០ម៉ឺនដុល្លារអាមេរិក ទេ យោងតាមអ្នកនាំពាក្យសេតវិមាន



*ប្រភព៖ Reuters News, 2021 (https://www.reuters.com/article/us-usa-biden-taxes/biden-would-not-raise-taxes-on-anyone-making-less-than-400000-white-house-idUSKBN2B72CV), REUTERS/Cheriss May, March 14, 2021*

យោងតាមអ្នកនាំពាក្យសេតវិមានលោកស្រី Jen Psaki បានឱ្យដឹងថា ប្រធានាធិបតីសហរដ្ឋអាមេរិកលោក Joe Biden នៅតែប្តេជ្ញាចំពោះការសន្យាអំឡុងពេលធ្វើយុទ្ធនាការបោះឆ្នោតរបស់លោកថា គ្មាននរណាម្នាក់ដែលរកប្រាក់ចំណូលបានតិចជាង ៤០០,០០០ដុល្លារអាមេរិក អាចនឹងឃើញមានការតម្លើងពន្ធលើប្រាក់ចំណូលរបស់ពួកគេនោះឡើយ។

លោកស្រីបញ្ជាក់ថា រដ្ឋបាលរបស់លោក Biden កំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយនឹងសមាជិកសភាអំពីវិធីដែល

ល្អបំផុត ដើម្បីផ្តល់ឱកាសសម្រាប់កញ្ចប់ហេដ្ឋារចនាសម្ព័ន្ធ ប្រកបដោយមហិច្ឆតានេះ។ ប៉ុន្តែ ផែនការទាំងនោះមិនទាន់ត្រូវបានបញ្ចប់នៅឡើយទេ។

លោកស្រីបញ្ជាក់ទៀតថា «អាទិភាព និងការផ្តោតសំខាន់របស់លោកប្រធានាធិបតី គឺថាប្រជាពលរដ្ឋអាមេរិកនឹងបង់ពន្ធសមស្របទៅតាមចំណែករបស់ពួកគេ និងផ្តោតសំខាន់ផងដែរ ចំពោះសាជីវកម្មទាំងឡាយដែលមិនបង់ពន្ធសមស្របទៅតាមចំណែករបស់ពួកគេ»៕

*ដោយ ស៊ិន សុភារ៉ា*

*ប្រភព៖ គេហទំព័រសារព័ត៌មាន reuters ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ ២០២១*

## ទិន្នន័យស្រាវជ្រាវសម្រាប់សប្តាហ៍បន្ទាប់

ទិន្នន័យសម្រាប់សប្តាហ៍ខាងមុខនេះ រួមមាន៖សន្ទស្សន៍សេដ្ឋកិច្ចនាំមុខគេ និងការវិនិយោគភាគហ៊ុនដោយជនបរទេសនៅប្រទេសជប៉ុន សន្ទស្សន៍សកម្មភាពជាតិរបស់ធនាគារឈីកាហ្គោ ការលក់ផ្ទះថ្មី និងការបម្រែបម្រួលភាគហ៊ុនប្រេងឆៅ API នៅសហរដ្ឋអាមេរិក សូចនាករវដ្តអាជីវកម្មឈានមុខគេរបស់ប្រទេសអាហ្វ្រិកខាងត្បូង អត្រានិកម្មភាពនៅប្រទេសម៉ិចស៊ិក សូចនាករបរិយាកាសអាជីវកម្មរបស់ប្រទេសបារាំង ទំនុកចិត្តអ្នកប្រើប្រាស់នៅប្រទេសកូរ៉េខាងត្បូង កំណើនប្រាក់កម្ចីនៅប្រទេសឥណ្ឌា៕

ខាងក្រោម គឺជាប្រតិទិនដែលនាយកដ្ឋានស្រាវជ្រាវថវិកានឹងបន្តតាមដាននៅសប្តាហ៍ក្រោយ៖

<u>ថ្ងៃចន្ទ ទី២២ ខែមីនា ឆ្នាំ២០២១</u>

- សន្ទស្សន៍សេដ្ឋកិច្ចនាំមុខគេ នៅប្រទេសជប៉ុន សម្រាប់ខែមករា
- សន្ទស្សន៍សកម្មភាពជាតិរបស់ធនាគារឈីកាហ្គោ នៅសហរដ្ឋអាមេរិក សម្រាប់ខែកុម្ភៈ

<u>ថ្ងៃអង្គារ ទី២៣ ខែមីនា ឆ្នាំ២០២១</u>

- សូចនាករវដ្តអាជីវកម្មឈានមុខគេរបស់ប្រទេសអាហ្វ្រិកខាងត្បូង ធៀបនឹងខែមុន សម្រាប់ខែមករា
- ការលក់ផ្ទះថ្មីនៅសហរដ្ឋអាមេរិក សម្រាប់ខែកុម្ភៈ

<u>ថ្ងៃពុធ ទី២៤ ខែមីនា ឆ្នាំ២០២១</u>

- ការបម្រែបម្រួលភាគហ៊ុនប្រេងឆៅ API នៅសហរដ្ឋអាមេរិក សម្រាប់ថ្ងៃទី១៩ ខែមីនា
- អត្រានិកម្មភាពនៅប្រទេសម៉ិចស៊ិក សម្រាប់ខែកុម្ភៈ

<u>ថ្ងៃព្រហស្បតិ៍ ទី២៥ ខែមីនា ឆ្នាំ២០២១</u>

- ការវិនិយោគភាគហ៊ុនដោយជនបរទេសនៅប្រទេសជប៉ុន សម្រាប់ថ្ងៃទី២០ ខែមីនា
- សូចនាករបរិយាកាសអាជីវកម្មរបស់ប្រទេសបារាំង សម្រាប់ខែមីនា

<u>ថ្ងៃសុក្រ ទី២៦ ខែមីនា ឆ្នាំ២០២១</u>

- ទំនុកចិត្តអ្នកប្រើប្រាស់នៅប្រទេសកូរ៉េខាង ត្បូង សម្រាប់ខែមីនា
- កំណើនប្រាក់កម្ចីនៅប្រទេសឥណ្ឌា ធៀបនឹង ឆ្នាំមុន សម្រាប់ថ្ងៃទី១២ ខែមីនា